**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

លេខ: ២១៩៩ក.ក.ល

ថ្ងៃពុធ ១កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការអញ្ជើញចូលរួមបង្ហាញចំណាប់អារម្មណ៍

សូមអញ្ជើញក្រុមហ៊ុន/យានដ្ឋាន ដែលមានលក្ខណៈសម្បត្តិ ចូលរួមបង្ហាញចំណាប់អារម្មណ៍ស្ដីពីការផ្ដល់សេវាជួសជុលរថយន្ត សម្រាប់រយៈពេល១ឆ្នាំ។

ក្រុមហ៊ុន/យានដ្ឋាន ទាំងអស់ដែលមានចំណាប់អារម្មណ៍ អាចទាក់ទងជាមួយអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ឯកសារបង្ហាញពីចំណាប់អារម្មណ៍ ត្រូវបានផ្ដល់ជូនក្រុមហ៊ុន/យានដ្ឋានដោយមិនគិតថ្លៃ ក្នុងរយៈពេល១៤ថ្ងៃ ចាប់ពីថ្ងៃព្រហស្បតិ៍ ទី១៤ ខែធ្នូ ឆ្នាំ២០២៣ ដល់ថ្ងៃ ពុធ ទី ២៧ខែធ្នូ ឆ្នាំ២០២៣ ។

ក្រុមហ៊ុន/យានដ្ឋានត្រូវបំពេញឯកសារបង្ហាញពីចំណាប់អារម្មណ៍ហើយប្រគល់ជូនអង្គភាពលទ្ធកម្ម ចាប់ពីថ្ងៃ ព្រ.ហ ទី ២៨ ខែធ្នូ ឆ្នាំ២០២៣ ដល់ថ្ងៃពុធ ទី១០ ខែមករា ឆ្នាំ២០២៤ រៀងរាល់ម៉ោងធ្វើការ។

សំណើបង្ហាញពីចំណាប់អារម្មណ៍របស់ក្រុមហ៊ុន/យានដ្ឋានទាំងអស់មិនតម្រូវឱ្យមានប្រាក់កក់ធានាឡើយ។ ក្រុមហ៊ុន/យានដ្ឋានដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើបង្ហាញពីចំណាប់អារម្មណ៍បានតែមួយគត់។

ក្រុមហ៊ុន/យានដ្ឋានដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងត្រូវបានអញ្ជើញដើម្បីអនុវត្តនីតិវិធីបន្តក្នុងការផ្ដល់សេវាជួសជុលរថយន្តសម្រាប់រយៈពេល១ឆ្នាំ ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

សម្រាប់រាល់ព័ត៌មានលំអិតសូមអញ្ជើញទាក់ទងអង្គភាពលទ្ធកម្មដូចមានអាសយដ្ឋានខាងលើ ឬ តាមទូរស័ព្ទលេខ: ០១៧ ៨១១ ៩១១។

**ជ. គណៈកម្មាធិការលទ្ធកម្ម**

**អនុប្រធាន**

**ជូ ផល្លា**

"ដើម្បីជ្រាបជាព័ត៌មាន"

-ឯកសារ-កាលប្បវត្តិ

អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh